**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់
## អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៧ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៣២ ចុះថ្ងៃទី ០២ ខែ មិនា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ និងមាត្រា៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៧ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ (អ.គ.ជ.ប.អ) ។

## ជំពូកទី ២

## តួនាទី និងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ មានតួនាទី និងភារកិច្ចដូចតទៅ:

- ទទួលបន្ទុកចាត់ការទូទៅ គ្រប់គ្រងនិងសម្របសម្រួលរាល់សកម្មភាព និង ការងារប្រចាំថ្ងៃរបស់ គ.ជ.ប.អ
- លើកផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និង ផែនការថវិការបស់ គ.ជ.ប.អ
- សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍នានាជាពិសេសមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន លើរាល់សកម្មភាពដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ
- សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍នានា លើរាល់សកម្មភាពអភិវឌ្ឍន៍សហគមន៍តាមរយៈការចងក្រង កែលំអនិងពង្រឹងសមត្ថភាព និងផ្តល់ឥណទាន ។ល។
- សម្របសម្រួល និងសហការជាមួយគណៈកម្មការនៃរដ្ឋសភានិងព្រឹទ្ធសភាក្នុងក្របខ័ណ្ឌជាតិអំពីបញ្ហាប្រជាជននិងការអភិវឌ្ឍ ដោយរៀបចំសិក្ខាសាលា និងផ្សព្វផ្សាយនូវគោលការណ៍ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិដែលរាជរដ្ឋាភិបាលបានចុះហត្ថលេខា
- ស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយឯកសារគោលនយោបាយ ផែនការ កម្មវិធី និងសេចក្តីប្រកាសនានា ដែលទាក់ទងនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍ

- តាមដាន វាយតម្លៃ និងលើកអនុសាសន៍ក្នុងការកែសម្រួលគោលនយោបាយជាតិប្រជាជន ដើម្បីឱ្យការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រជាតិនានា ដែលពាក់ព័ន្ធឱ្យកាន់តែល្អប្រសើរស្របតាមការវិវត្តនៃសភាពការណ៍ក្នុងប្រទេស តំបន់ និងពិភពលោក
- បណ្តុះបណ្តាលបច្ចេកទេសដើម្បីលើកកម្ពស់ការយល់ដឹងក្នុងការវិភាគ ត្រួតពិនិត្យតាមដាន និងវាយតម្លៃរាល់បញ្ហាទាក់ទងនឹងប្រជាជន តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលាជាតិ និងអន្តរជាតិ
- រាយការណ៍ជូនប្រធានពីសកម្មភាពការងារសំខាន់ៗ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានប្រគល់ជូន។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដំណើរការការងាររបស់ខ្លួន។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈ ដែលប្រាក់បៀវត្សនិងប្រាក់បំណាច់ផ្សេងៗ ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ អាចមានអ្នកជំនាញការ ឬ បុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងាររបស់ខ្លួន។

មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ អាចទទួលប្រាក់ឧបត្ថម្ភផ្សេងៗដែលផ្តល់មកពីក្នុងនិងក្រៅប្រទេស ឬ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាដែលផ្តល់ជំនួយ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ និងការគ្រប់គ្រង

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងជាជំនួយការ និងមាននាយកដ្ឋានមួយចំនួនតាមការចាំបាច់ ។

នាយកដ្ឋានត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ មានរចនាសម្ព័ន្ធដូចខាងក្រោម:

១- នាយកដ្ឋានរដ្ឋបាល និងគណនេយ្យ

២- នាយកដ្ឋានផ្សព្វផ្សាយ និងព័ត៌មាន

៣- នាយកដ្ឋានបណ្តុះបណ្តាល និងការអភិវឌ្ឍ

៤- នាយកដ្ឋានវិភាគគោលនយោបាយប្រជាជន

៥- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ មានភារកិច្ចលើកសំណើជូនប្រធាន គ.ជ.ប.អ ដើម្បីពិនិត្យនិងសម្រេចអំពីការផ្លាស់ប្តូរ ឬ បង្កើតនាយកដ្ឋានផ្សេងៗទៀតតាមតម្រូវការចាំបាច់។

**មាត្រា ៨.-**

នាយករដ្ឋបាល និងគណនេយ្យមានភារកិច្ចដូចតទៅ:

- ទទួលខុសត្រូវលើសេវាកម្មទូទៅក្នុងផ្នែករដ្ឋបាល និងសម្របសម្រួលការងាររដ្ឋបាល
- ទទួលខុសត្រូវលើសំណុំលិខិត ឯកសារ លិខិតបទដ្ឋាននានា និងតម្កល់ឯកសារ
- គ្រប់គ្រងឯកសារ មន្ត្រីរាជការបុគ្គលិក និងការងារអភិវឌ្ឍធនធានមនុស្សក្នុងអគ្គលេខាធិការដ្ឋាន
- ទទួលបន្ទុករៀបចំកិច្ចប្រជុំ ឬសិក្ខាសាលា និងធ្វើរបាយការណ៍ឬកំណត់ហេតុពីសកម្មភាពនានា
- រៀបចំគម្រោងថវិកា សម្ភារៈបរិក្ខា និងមធ្យោបាយនានាប្រចាំឆ្នាំរបស់ គ.ជ.ប.អ
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិសម្ភារៈរបស់ គ.ជ.ប.អ
- លើកគម្រោងជួសជុល ផ្គត់ផ្គង់ និងថែទាំអចលនទ្រព្យ ចលនទ្រព្យ
- ប្រតិបត្តិថវិកាទៅតាមគោលការណ៍លទ្ធកម្ម និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារពាក់ព័ន្ធប្រាក់បៀវត្ស ស្នើប្រាក់ឧបត្ថម្ភផ្សេងៗជូនមន្ត្រីរាជការនិងបុគ្គលិក
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ៩.-**

នាយកដ្ឋានផ្សព្វផ្សាយ និងព័ត៌មានមានភារកិច្ចដូចតទៅ:

- ផ្សព្វផ្សាយព័ត៌មានស្តីពីឯកសារ គោលនយោបាយ ផែនការ កម្មវិធី និងសេចក្តីប្រកាសដែលទាក់ទងនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍ និងទិន្នន័យរួមទាំងអត្ថបទបោះពុម្ពផ្សាយ សៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តី ផ្ទាំងរូបភាព ការពិភាក្សាតុមូល ខ្សែវីដេអូផ្សេងៗ
- ពន្យល់និងផ្តល់ព័ត៌មានអំពីគំនិតនៃគោលនយោបាយជាតិប្រជាជន ដល់អ្នកធ្វើគោលនយោបាយ និងអ្នកធ្វើផែនការ អ្នកធ្វើការសម្រេចចិត្តថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីឱ្យមានការគាំទ្រ និងអនុវត្តគោលនយោបាយជាតិប្រជាជនឱ្យមានប្រសិទ្ធភាព
- ចូលរួមនិងរៀបចំធ្វើបទបង្ហាញ ការត្រួតពិនិត្យគោលនយោបាយ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍនៅក្នុងសន្និសីទជាតិ ដើម្បីទទួលបានការគាំទ្រពីស្ថាប័នពាក់ព័ន្ធនានា

- សម្របសម្រួល និងសហការជាមួយគណៈកម្មការនៃរដ្ឋសភានិងព្រឹទ្ធសភាក្នុងក្របខ័ណ្ឌជាតិអំពីបញ្ហាប្រជាជននិងការអភិវឌ្ឍ ដើម្បីជាជំនួយក្នុងការសម្រេចគោលដៅ កម្មវិធី គោលនយោបាយរបស់រាជរដ្ឋាភិបាល
- ចូលរួមក្នុងសន្និសីទនិងកិច្ចប្រជុំជាតិនិងអន្តរជាតិ និងសហការរៀបចំឯកសារសំខាន់ៗស្តីពី បញ្ហាប្រជាជននិងការអភិវឌ្ឍ
- រៀបចំពិធីសារ សេចក្តីប្រកាស និង ដំណោះស្រាយនានាពាក់ព័ន្ធនឹងបញ្ហាប្រជាជនដូចជាសុខភាពបន្តពូជ មនុស្សចាស់ និងយេនឌ័រជាដើម
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១០.-**

នាយកដ្ឋានបណ្តុះបណ្តាល និងការអភិវឌ្ឍ មានភារកិច្ចដូចតទៅៈ

- ចូលរួមនិងរៀបចំវគ្គបណ្តុះបណ្តាលជូនដល់អ្នកធ្វើគោលនយោបាយ អ្នកធ្វើការសម្រេចចិត្ត និងអ្នកធ្វើផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីបញ្ជ្រាបនិងបង្កើនចំណេះដឹង និងស្វែងយល់អំពីទំនាក់ទំនងរវាងបញ្ហាប្រជាជននិងការអភិវឌ្ឍ
- រៀបចំកម្មវិធីបណ្តុះបណ្តាល ដើម្បីបង្កើតយន្តការផ្លាស់ប្តូរបទពិសោធន៍ និងទស្សនៈជាវិជ្ជមាន និងកម្មវិធីថ្មីៗដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍក្នុងតំបន់ក៏ដូចជាក្រៅតំបន់
- បណ្តុះបណ្តាលបច្ចេកទេស និងចំណេះដឹងក្នុងការវិភាគ ត្រួតពិនិត្យតាមដាន និងមានលទ្ធភាពវាយតម្លៃនូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍ តាមរយៈការចូលរួមនិងផ្តល់សិក្ខាសាលាថ្នាក់ជាតិនិងអន្តរជាតិ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១១.-**

នាយកដ្ឋានវិភាគគោលនយោបាយប្រជាជន មានភារកិច្ចដូចតទៅៈ

- ស្រាវជ្រាវពីបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍជូនរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននិងអង្គភាពពាក់ព័ន្ធនានា
- ពិនិត្យ និងស្រាវជ្រាវពីគម្លាតខុសគ្នារវាងទិន្នន័យនិងទិដ្ឋភាពជាក់ស្តែង និងពង្រឹងសមត្ថភាពក្នុងការស្រាវជ្រាវអំពីបញ្ហានានានៅក្នុងគោលនយោបាយជាតិប្រជាជន និង គោលនយោបាយពាក់ព័ន្ធនានាដែលកើតមានឡើងដូចជាការបំលាស់ទី មនុស្សចាស់ នគរូបនីយកម្មជាដើម។

- រៀបចំស្តូចនាករណ៍សម្រាប់ការអនុវត្តគោលនយោបាយជាតិប្រជាជន ដែលបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- អភិវឌ្ឍមជ្ឈមណ្ឌលប្រមូលស្ថិតិព័ត៌មាននិងទិន្នន័យទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ១២.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ មានភារកិច្ចដូចតទៅ:

- កំណត់ស្តូចនាករណ៍ ស្រាវជ្រាវ និងអង្កេតអំពីសហគមន៍ក្រីក្រនៅរាជធានី ខេត្ត ក្រុង
- សម្របសម្រួល និងធ្វើការសហការជាមួយរដ្ឋបាលមូលដ្ឋានក្នុងការកំណត់ឱ្យបាននូវសហគមន៍ក្រីក្រដែលត្រូវការកែលំអ និងអភិវឌ្ឍ
- ស្វែងរកមូលនិធិជាតិនិងអន្តរជាតិ ដើម្បីបង្កើតជាទុនសម្រាប់ការធ្វើឥណទានដល់ប្រជាជនរស់នៅសហគមន៍ក្រីក្រ
- ជំរុញការសន្សំប្រាក់ និងផ្តល់ឥណទានមានការប្រាក់ទាបដល់សហគមន៍តាមតម្រូវការជាក់ស្តែង
- រៀបចំ ចងក្រងនិងកែលំអសហគមន៍ក្រីក្រឱ្យសម្រេចបានតាមគោលការណ៍ និងគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា "១០០ សហគមន៍ក្នុងមួយឆ្នាំ"
- រៀបចំចងក្រងនិងពង្រឹងសមត្ថភាពសហគមន៍
- ពង្រឹងភាពជាដៃគូ ក្នុងសហគមន៍នៅថ្នាក់មូលដ្ឋាន តំបន់ ជាតិ និង អន្តរជាតិ
- រៀបចំ និង ជម្រុញឱ្យមានការផ្លាស់ប្តូរនិងដកស្រង់យកបទពិសោធន៍ល្អៗពីសហគមន៍មួយទៅសហគមន៍មួយទៀតតាមរយៈទស្សនៈកិច្ចសិក្សា និងកិច្ចប្រជុំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា១៣.-**

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ រដ្ឋលេធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តន៍ អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ